**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ១៦២...អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការកែប្រែឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីជលផល
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្ដីពីការបង្កើតតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្ដីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គិរីរម្យ»

- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា១ .-**

ត្រូវបានកែប្រែឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» ពីផ្ទៃដីទំហំ១៥៤ ៤៥៨(មួយសែនប្រាំម៉ឺនបួនពាន់បួនរយហាសិបប្រាំបី)ហិកតា មកផ្ទៃដីទំហំ១៥៦ ១១៦(មួយសែនប្រាំម៉ឺនប្រាំមួយពាន់មួយរយដប់ប្រាំមួយ)ហិកតា ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពត ខេត្តកំពង់ស្ពឺ និងខេត្តព្រះសីហនុ ដូចមានផែនទីភ្ជាប់ក្នុងឧបសម្ព័ន្ធ១និងនិយាមកា(តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984)ភ្ជាប់ក្នុងឧបសម្ព័ន្ធ២នៃអនុក្រឹត្យនេះ។

ផ្ទៃដីឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»ខាងលើ បានមកពីការបូកបញ្ចូលផ្ទៃដីទំហំ១៥៤ ៤៥៨(មួយសែនប្រាំម៉ឺនបួនពាន់បួនរយហាសិបប្រាំបី)ហិកតា ដែលមានចែងក្នុងអនុក្រឹត្យលេខ១៧១ អនក្រ.បក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ «គិរីរម្យ» ហើយនិងផ្នែកខ្លះនៃរបៀងអភិរក្សជីវៈចម្រុះជួរភ្នំក្រវាញ ដែលមានផ្ទៃដីទំហំ១ ៦៥៨(មួយពាន់ប្រាំមួយរយហាសិបប្រាំបី)ហិកតា ដូចមានចែងក្នុងអនុក្រឹត្យលេខ០៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅ៖

- ធានាការថែរក្សា ការពារសោភណភាពធម្មជាតិ និងទេសភាព ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ សម្រាប់វិទ្យាសាស្ត្រ ការអប់រំ ការសិក្សាស្រាវជ្រាវ និងការកម្សាន្ត
- លើកកម្ពស់តួនាទី សក្តានុពល និងកិត្យានុភាពនៃប្រព័ន្ធអេកូឡូស៊ី ឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ដោយចីរភាព
- រក្សាលំនឹងបរិស្ថាន និងរួមចំណែកកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងហានិភ័យគ្រោះមហន្តរាយធម្មជាតិ
- ផ្តល់ផលិតផលនិងសេវាកម្មធម្មជាតិសម្រាប់ការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ជំរុញនិងលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមនិងសហគមន៍មូលដ្ឋាន ដើម្បីរួមចំណែកក្នុងកិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការការពារធនធានធម្មជាតិ និងការរស់នៅដោយចីរភាព
- លើកកម្ពស់ការចូលរួមរបស់សហគមន៍មូលដ្ឋាន ក៏ដូចជាសាធារណជនក្នុងការចូលរួមចំណែកដល់ការគ្រប់គ្រង ការការពារ និងការអភិរក្សជីវៈចម្រុះ និងធនធានធម្មជាតិក្នុងតំបន់។

**មាត្រា៣ .-**

ក្រសួងបរិស្ថានមានសមត្ថកិច្ចរៀបចំ កែប្រែ និងគ្រប់គ្រងតំបន់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ» ដោយសហការជាមួយក្រសួង ស្ថាប័ន រដ្ឋបាលខេត្តកំពត រដ្ឋបាលខេត្តកំពង់ស្ពឺ និងរដ្ឋបាលខេត្តព្រះសីហនុ ដើម្បីធានាដល់ការគ្រប់គ្រងបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព និងការរស់នៅដោយចីរភាព ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៤ ._**

លិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការកំណត់តំបន់សហគមន៍ តំបន់ប្រើប្រាស់ដោយចីរភាព ការវិនិយោគ ការចេញប័ណ្ណដីធ្លី ឬការអនុញ្ញាតឱ្យប្រើប្រាស់ដីធ្លី ដែលអនុលោមតាមព្រះរាជក្រឹត្យស្តីពីការបង្កើតតំបន់ការពារធម្មជាតិ អនុក្រឹត្យស្តីពីការកំណត់តំបន់ឧទ្យានជាតិព្រះមុនីវង្ស«បូកគោ»និងឧទ្យានជាតិព្រះសុរាម្រិត-កុសមៈ«គិរីរម្យ» អនុក្រឹត្យស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ត្រូវមានអានុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួសស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

**មាត្រា៥ ._**

អនុក្រឹត្យលេខ០៧ អនក្រ.បក ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៧ ស្តីពីការបង្កើតរបៀងអភិរក្សជីវៈចម្រុះប្រព័ន្ធតំបន់ការពារធម្មជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៦ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តកំពត អភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១៥ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**សាយ សំអាល់**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ១៦២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០២៣

ផែនទីឧទ្យានជាតិព្រះមុនីវង្ស «បូកគោ» ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពត ខេត្តព្រះសីហនុ និងខេត្តកំពង់ស្ពឺ






សញ្ញាសម្គាល់

- ចំណុចនីយាមកា
- ព្រំប្រទល់ខេត្ត
- ព្រំប្រទល់តំបន់ការពារធម្មជាតិ

មាត្រដ្ឋាន 1:250,000

0 2.5 5 10 km

Map Coordinate System:
Units: meters
System Projection: UTM, Zone 48 N
Datum: WGS 1984

ឧទ្យានជាតិព្រះមុនីវង្ស «បូកគោ»

មានផ្ទៃដីទំហំ ១៥៦ ១១៦ហិកតា

ប្រភពទិន្នន័យ

ខ្សែព្រំប្រទល់តំបន់ការពារធម្មជាតិ : ក្រសួងបរិស្ថាន

ព្រំប្រទល់រដ្ឋបាល : ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (២០២១)

រូបភាព : Google Earth

រៀបរៀងដោយ : នាយកដ្ឋានសេវាកម្មព័ត៌មានភូមិសាស្ត្រនៃក្រសួងបរិស្ថាន

ឧបសម្ព័ន្ធ២នៃអនុក្រឹត្យលេខ ១៦២ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣

ចំណុចនិយាមការនៃផែនទីឧទ្យានជាតិព្រះមុនីវង្ស «បូកគោ»

| ID | X | Y |
|---|---|---|
| 1 | 370181 | 1218897 |
| 2 | 370296 | 1217212 |
| 3 | 369643 | 1218069 |
| 4 | 368608 | 1218617 |
| 5 | 369137 | 1219315 |
| 6 | 369860 | 1220705 |
| 7 | 370624 | 1222050 |
| 8 | 371196 | 1222084 |
| 9 | 370576 | 1220325 |
| 10 | 377793 | 1224710 |
| 11 | 378599 | 1223305 |
| 12 | 380013 | 1222193 |
| 13 | 379346 | 1220196 |
| 14 | 378913 | 1218836 |
| 15 | 379681 | 1217344 |
| 16 | 380190 | 1216106 |
| 17 | 381013 | 1214696 |
| 18 | 380041 | 1216565 |
| 19 | 379241 | 1217810 |
| 20 | 379093 | 1219238 |
| 21 | 378805 | 1220684 |
| 22 | 376867 | 1221876 |
| 23 | 376106 | 1223253 |
| 24 | 376344 | 1224603 |
| 25 | 382727 | 1221164 |
| 26 | 384001 | 1224997 |
| 27 | 387582 | 1227344 |
| 28 | 389584 | 1229212 |
| 29 | 389606 | 1231820 |
| 30 | 392024 | 1231837 |
| 31 | 393762 | 1228319 |
| 32 | 395143 | 1228320 |
| 33 | 396368 | 1230473 |
| 34 | 396371 | 1232787 |
| 35 | 394801 | 1233809 |
| 36 | 394849 | 1236210 |
| 37 | 395147 | 1237247 |
| 38 | 398699 | 1237586 |
| 39 | 401066 | 1238616 |
| 40 | 403295 | 1238498 |
| 41 | 403302 | 1235761 |
| 42 | 404241 | 1234672 |
| 43 | 403894 | 1233154 |
| 44 | 406133 | 1231902 |

| ID | X | Y |
|---|---|---|
| 45 | 407581 | 1225785 |
| 46 | 407581 | 1221239 |
| 47 | 407581 | 1216206 |
| 48 | 403562 | 1210306 |
| 49 | 403620 | 1206297 |
| 50 | 404468 | 1200315 |
| 51 | 404579 | 1198318 |
| 52 | 406266 | 1194312 |
| 53 | 407592 | 1186343 |
| 54 | 407993 | 1184103 |
| 55 | 408673 | 1183399 |
| 56 | 408289 | 1181603 |
| 57 | 407701 | 1180428 |
| 58 | 407333 | 1178866 |
| 59 | 405367 | 1179592 |
| 60 | 405989 | 1177947 |
| 61 | 406107 | 1175836 |
| 62 | 404089 | 1173355 |
| 63 | 405084 | 1170376 |
| 64 | 402391 | 1168976 |
| 65 | 401405 | 1169336 |
| 66 | 399117 | 1168772 |
| 67 | 398372 | 1169742 |
| 68 | 394765 | 1171375 |
| 69 | 390773 | 1171317 |
| 70 | 389431 | 1171075 |
| 71 | 386755 | 1172006 |
| 72 | 384389 | 1174054 |
| 73 | 383626 | 1174715 |
| 74 | 383777 | 1175754 |
| 75 | 381756 | 1179340 |
| 76 | 380292 | 1183642 |
| 77 | 379463 | 1184486 |
| 78 | 379613 | 1185926 |
| 79 | 378102 | 1187825 |
| 80 | 378092 | 1190403 |
| 81 | 377612 | 1192958 |
| 82 | 376737 | 1195943 |
| 83 | 376753 | 1197990 |
| 84 | 376834 | 1200587 |
| 85 | 377189 | 1203150 |
| 86 | 378757 | 1206174 |
| 87 | 380152 | 1207076 |
| 88 | 381902 | 1208893 |

| ID | X | Y |
|---|---|---|
| 89 | 384312 | 1209524 |
| 90 | 383640 | 1215402 |
| 91 | 382273 | 1214866 |
| 92 | 381495 | 1214765 |
| 93 | 381339 | 1216098 |
| 94 | 382468 | 1216570 |
| 95 | 381981 | 1216112 |
| 96 | 383408 | 1215689 |
| 97 | 383688 | 1216133 |
| 98 | 383777 | 1217516 |
| 99 | 383272 | 1218718 |